# ព្រះរាជក្រម

នស / រកម / ០៩០២ / ០១៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)
ចូល
លេខ......1420......
ថ្ងៃទី......
បញ្ជាការ......

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារ នៃការអនុវត្តន៍កញ្ចប់ទីពីរ នៃកិច្ចសន្យាវិស័យសេវាហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ ទី ២១ ខែ សីហា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ១ ។

ច្បាប់នេះមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់ស្តីពី

# ការអនុម័តយល់ព្រមលើពិធីសារនៃការអនុវត្តន៍កញ្ចប់ទីពីរនៃកិច្ច សន្យាក្នុងវិស័យសេវាហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ អាស៊ានស្តីពីសេវាកម្ម

**មាត្រា១.–**

អនុម័តយល់ព្រមលើពិធីសារនៃការអនុវត្តន៍កញ្ចប់ទីពីរនៃកិច្ចសន្យាក្នុងវិស័យសេវាហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្មដែលត្រូវបានចុះហត្ថលេខា នៅទីក្រុងយ៉ាំងហ្គូន ប្រទេសមីយ៉ាន់ម៉ា នាថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០០២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី២៥ខែកញ្ញា ឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និង ត្រា**

**ជា ស៊ីម**

នសរ.០២.០៩.០០២៤៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី លេខៈ ១៩៨ ច.ល

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចម្លងចែក

**ហត្ថលេខា**

**គាត ឈន់**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០២

# ពិធីសារ

## ស្តីពីការអនុវត្តន៍កញ្ចប់ទីពីរនៃការសន្យាក្នុងវិស័យសេវាហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡាំ ព្រះរាជាណាចក្រកម្ពុជា សាធារណៈរដ្ឋឥណ្ឌូនេស៊ី សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ារ សាធារណៈរដ្ឋហ្វីលីពីន សាធារណៈរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណៈរដ្ឋសង្គមនិយមវៀតណាម ដែលជាប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (ដែលពីពេលនេះទៅហៅកាត់ថា អាស៊ាន)

ដោយកត់សំគាល់ថា កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ នៅទីក្រុងបាងកក ប្រទេសថៃ មានបំណងលើកកំពស់កិច្ចសហប្រតិបត្តិការវិស័យសេវា ក្នុងចំណោមប្រទេសជាសមាជិក ដើម្បីលុបបំបាត់រាំងពាណិជ្ជកម្មអោយបានកាន់តែច្រើននៅក្នុងវិស័យសេវាទាំងអស់ ក្នុងចំណោមប្រទេសជាសមាជិក និង ដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មនៅក្នុងវិស័យសេវា ដោយធ្វើអោយស៊ីជំរៅ និង ពង្រីកវិសាលភាពនៃសេរីភាវូបនីយកម្មអោយបានខ្លាំងជាង ការធ្វើសេរីភាវូបនីយកម្ម ដែលប្រទេសជាសមាជិកត្រូវអនុវត្តតាមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មក្នុងវិស័យសេវា (ពីនេះទៅ ហៅកាត់ថា "GATS") នៃអង្គការពាណិជ្ជកម្មពិភពលោក (ពីនេះទៅ ហៅកាត់ថា "WTO")

ដោយរំលឹកឡើងវិញថា កិច្ចប្រជុំកំពូលអាស៊ានលើកទី៦បានអំពាវនាវអោយប្រទេសជាសមាជិកចូលរួមក្នុងកិច្ចចរចាជាលើកទី ២ ដែលចាប់ផ្តើមនៅឆ្នាំ ១៩៩៩ និងបញ្ចប់នៅឆ្នាំ ២០០១ ដែលគ្របដណ្តប់ផ្នែកសេវាទាំងអស់ និង គ្រប់ប្រភេទនៃការផ្តល់សេវា។

ដោយបាន ដំណើរការកិច្ចចរចាជាបន្តបន្ទាប់ក្នុងវិស័យសេវាហិរញ្ញវត្ថុ តាមមាត្រាទី៤ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា និង ដោយបានបញ្ចប់នូវកញ្ចប់សន្យានៅក្នុងកិច្ចចរចាជុំទី២ ស្តីពីសេវាហិរញ្ញវត្ថុ។

ដោយប្រឹងប្រែង ដើម្បីធានាថា ប្រទេសសមាជិកអាស៊ានដែលមិនមែនជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ក៏ត្រូវតែផ្តល់ប្រព្រឹត្តកម្មដូចគ្នាក្នុងវិស័យសេវាហិរញ្ញវត្ថុ ដូចគ្នានឹងប្រទេសសមាជិកអាស៊ាន ដែលជាសមាជិកអង្គការ WTO ផ្តល់អោយសមាជិក WTO ទាំងអស់ដែរ។

**ហោយមានចំណង់** បង្កើតអោយមាននូវបញ្ជីសន្យាស្តីពីសេវាហិរញ្ញវត្ថុ ដែលប្រទេសសមាជិកនីមួយៗត្រូវអនុវត្ត និងដើម្បីអោយប្រទេសសមាជិកនីមួយៗ ផ្តល់ប្រព្រឹត្តកម្មអនុគ្រោះទៅវិញទៅមក ដោយឈរលើមូលដ្ឋាននៃប្រព័ន្ធអនុគ្រោះបំផុត (MFN)

**បានព្រមព្រៀងដូចខាងក្រោម :**

១- ប្រទេសជាសមាជិកអាស៊ាន ដែលជាសមាជិកអង្គការ WTO ត្រូវបន្តការសន្យាតាមវិស័យរបស់ខ្លួនក្រោម GATS ដល់ប្រទេសជាសមាជិកអាស៊ាន ដែលមិនមែនជាសមាជិកអង្គការ WTO ។

២- ប្រទេសជាសមាជិក ត្រូវផ្តល់ប្រព្រឹត្តកម្មអនុគ្រោះ ដល់ប្រទេសជាសមាជិកដទៃទៀត នៅក្នុងវិស័យសេវាហិរញ្ញវត្ថុ ដូចដែលមានចែងនៅក្នុងបញ្ជីសន្យាផ្តល់តាមវិស័យ ដែលបានភ្ជាប់ជាឧបសម្ព័ន្ធនៃពិធីសារនេះ ។

៣- ឧបសម្ព័ន្ធទាំងអស់ របស់ពិធីសារនេះ ត្រូវមានបញ្ជីសន្យាទូទៅ បញ្ជីសន្យាតាមវិស័យ និងបញ្ជីនៃការលើកលែង MFN ។

៤- ពិធីសារនេះ និង ឧបសម្ព័ន្ធរបស់វា គឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា ។

៥- ពិធីសារនេះ នឹងចូលជាធរមាន ពេលដែលឯកសារសច្ចានុម័ត ឬ ការយល់ព្រមដោយរដ្ឋាភិបាលជាហត្ថលេខីទាំងអស់ ត្រូវបានដាក់តំកល់នៅអគ្គលេខាធិការអាស៊ាន ដែលប្រព្រឹត្តទៅមិនត្រូវហួសពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២ ។

៦- ពិធីសារនេះ ត្រូវប្រគល់ជូនអគ្គលេខាធិការអាស៊ានដាក់តំកល់ទុក ដែលត្រូវផ្តល់ជាបន្ទាន់នូវច្បាប់ចំលងមួយច្បាប់ ដល់ប្រទេសជាសមាជិកនីមួយៗ ។ អគ្គលេខាធិការអាស៊ាន ក៏ត្រូវផ្តល់ជាបន្ទាន់ដងដែរ នូវការជូនដំណឹងអំពីការផ្តល់សច្ចាប័ន ឬ ការយល់ព្រមទាំងនោះ យោងតាមកថាខ័ណ្ឌទី ៩ នៃពិធីសារនេះ ដល់ប្រទេសសមាជិកនីមួយៗ ។

**ជាសក្ខីភាព** ហត្ថលេខីខាងក្រោម ដែលបានទទួលសិទ្ធិប្រទានត្រឹមត្រូវពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើពិធីសារស្តីពីការអនុវត្តន៍កញ្ចប់ទីពីរនៃការសន្យាក្នុងវិស័យសេវាហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា ។

**ធ្វើនៅ** យ៉ាងហ្គូន សហភាពមីយ៉ាន់ម៉ារ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០០២ ជាភាសាអង់គ្លេស តែមួយច្បាប់គត់ ។

**តំណាងរដ្ឋាភិបាលប្រ៊ុយណេ**

PEHIN DATO HJ. ABDUL AZIZ UMAR
រដ្ឋមន្ត្រីតំណាងក្រសួងហិរញ្ញវត្ថុ

តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

KEAT CHHON
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

តំណាងរដ្ឋាភិបាលសាធារណៈរដ្ឋឥណ្ឌូនេស៊ី

BOEDIONO
រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

តំណាងរដ្ឋាភិបាលសាធារណៈប្រជាធិបតេយ្យប្រជាមានិតឡាវ

SOUKANH MAHALAT
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

តំណាងរដ្ឋាភិបាលម៉ាឡេស៊ី

DATO'DR. SHAFIE HJ. MOHD. SALLEH
នាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

តំណាងរដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា

U KHIN MAUNG THEIN
រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និង ចំណូល

តំណាងរដ្ឋាភិបាលសាធារណៈរដ្ឋហ្វីលីពីន

JOSE ISIDRO N. CAMACHO
រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

តំណាងរដ្ឋាភិបាលសាធារណៈរដ្ឋសិង្ហបុរី

LIM HNG KIANG
រដ្ឋមន្ត្រីទី២ក្រសួងហិរញ្ញវត្ថុ

តំណាងរដ្ឋាភិបាលព្រះរាជាណាចក្រថៃឡង់ដ៍

SOMKID JATUSRIPITAK
រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

តំណាងរដ្ឋាភិបាលសាធារណៈរដ្ឋសង្គមនិយមវៀតណាម

LE THI BANG TAM
អនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

# PROTOCOL TO IMPLEMENT THE SECOND PACKAGE OF COMMITMENTS ON FINANCIAL SERVICES UNDER THE ASEAN FRAMEWORK AGREEMENT ON SERVICES

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Viet Nam, Member States of the Association of South East Asian Nations (hereinafter referred to as "ASEAN");

NOTING the ASEAN Framework Agreement on Services signed on 15 December 1995 in Bangkok, Thailand, which seeks to enhance cooperation in services amongst Member States, eliminate substantially restrictions to trade in services amongst Member States and liberalize trade in services by expanding the depth and scope of liberalization beyond those undertaken by Member States under the General Agreement on Trade in Services (hereinafter referred to as "GATS") of the World Trade Organization (hereinafter referred to as "WTO");

RECALLING that the Sixth ASEAN Summit called on Member States to enter into a second round of negotiations, beginning 1999 and ending 2001 to cover all services sectors and all modes of supply;

HAVING carried out negotiations in financial services pursuant to Article IV of the ASEAN Framework Agreement on Services and finalized the package of commitments under the second round of negotiations on financial services;

SEEKING to ensure that ASEAN Member States, who are non-WTO members, are also accorded the same treatment in financial services that ASEAN Member States, who are WTO members, extend to all members of the WTO;

CERTIFIED COPY
asean
SECRETARY GENERAL OF ASEAN

DESIRING to set out in a schedule, the specific commitments on financial services that each Member State shall undertake, for which Member States shall accord preferential treatment to one another on a Most-Favoured Nation basis;

## HAVE AGREED AS FOLLOWS:

1. Member States who are WTO Members shall continue to extend their specific commitments under GATS to ASEAN Member States who are non-WTO Members.

2. Member States shall extend to all other Member States preferential treatment in financial services as set forth in the Schedules of Specific Commitments annexed to this Protocol.

3. The Annexes to this Protocol shall consist of the Horizontal Commitments, Schedules of Specific Commitments and the Lists of Most-Favoured Nation Exemptions.

4. This Protocol and its Annexes shall form an integral part of the ASEAN Framework Agreement on Services.

5. This Protocol shall enter into force upon the deposit of instruments of ratification or acceptance by all signatory governments with the Secretary-General of ASEAN, which shall be done not later than 30 September 2002.

6. This Protocol shall be deposited with the Secretary-General of ASEAN who shall promptly furnish a certified copy thereof to each Member State. The Secretary-General of ASEAN shall also promptly furnish notifications of ratifications or acceptances made pursuant to paragraph 5 to each Member State.

IN WITNESS WHEREOF, the undersigned, being duly authorized thereto by their respective Governments, have signed the Protocol to Implement the Second Package of Commitments on Financial Services under the ASEAN Framework Agreement on Services.

DONE at Yangon, Myanmar on the 6th day of April 2002, in a single copy in the English language.

CERTIFIED COPY
SECRETARY GENERAL OF ASEAN

For the Government ~~of~~ Brunei Darussalam

PEHIN DATO HJ. ~~ABDUL AZIZ~~ UMAR
Minister ~~Representing~~ the Ministry of Finance

For the Government of the Kingdom of Cambodia

KEAT CHHON
Senior Minister, Minister of Economy and Finance

For the Government of the Republic of Indonesia

BOEDIONO
Minister of Finance

For the Government of the Lao People's Democratic Republic

SOUKANH MAHALATH
Minister of Finance

CERTIFIED COPY
SECRETARY GENERAL OF ASEAN

For the Government of Malaysia

DATO' DR. SHAFIE HJ. MOHD. SALLEH
Deputy Finance Minister I

For the Government of the Union of Myanmar

U KHIN MAUNG THEIN
Minister of Finance and Revenue

For the Government of the Republic of the Philippines

JOSE ISIDRO N. CAMACHO
Secretary of Finance

For the Government of the Republic of Singapore

LIM HNG KIANG
Second Minister for Finance

CERTIFIED COPY
SECRETARY GENERAL OF ASEAN
asean

For the Government of the Kingdom of Thailand

SOMKID JATUSRIPITAK
Deputy Prime Minister and Minister of Finance

For the Government of the Socialist Republic of Viet Nam

LE THI BANG TAM
Vice Minister of Finance

CERTIFIED COPY
SECRETARY GENERAL OF ASEAN